**ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ**

**THE STUDENT MOVEMENT FOR DEMOCRACY**

លេខ៖ ០០១៨/២០ ច.ន.ប្រ.

រដ្ឋធានីវ៉ាស៊ីនតុន ថ្ងៃទី២១ ខែសីហា ឆ្នាំ២០២០

# សេចក្តីថ្លែងការណ៍
## ច្រានចោលការបកស្រាយរបស់លោក ហ៊ុន សែន
## លើបញ្ហាបូរណភាពទឹកដី ព្រំដែនគោក ដែនសមុទ្រ កោះត្រល់ និង ចង្កោមកោះក្រចកសេះ

**ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ** សូមច្រានចោល នូវការបកស្រាយរបស់លោក **ហ៊ុន សែន** នាយករដ្ឋមន្ត្រីកម្ពុជា ជុំវិញបញ្ហាបូរណភាពទឹកដី ទាំងព្រំដែនគោក និងដែនសមុទ្រ នៃប្រទេសកម្ពុជា ជាមួយប្រទេសវៀតណាម កាលពីថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២០ ។ ការបញ្ជាដោយលោក **ហ៊ុន សែន** ឲ្យក្រសួងព័ត៌មានចាក់ចែងផ្សាយឡើងវិញ នូវសុន្ទរកថារយៈពេលជាង៥ម៉ោងរបស់គាត់ នៅឯកិច្ចប្រជុំរដ្ឋសភាជាតិ កាលពីថ្ងៃទី៩ ខែសីហា ឆ្នាំ២០១២ គឺមិនគ្រាន់តែមិនបានជម្រះមន្ទិលសង្ស័យក្នុងចិត្តប្រជាពលរដ្ឋខ្មែរ អំពីការបាត់បង់ទឹកដីព្រំដែនខ្មែរប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាការបង្ហាញនូវឥរិយាបថ ក្រោមឥទ្ធិពលវៀតណាម ដោយព្យាយាមបង្កើតខ្សែបន្ទាត់ព្រំដែនថ្មីរវាងកម្ពុជា-វៀតណាម ដែលខុសច្បាប់អន្តរជាតិ និង រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

លោក **ហ៊ុន សែន** មានកំហុសធ្ងន់ធ្ងរណាស់ ក្នុងការប្រកាន់យកកិច្ចព្រមព្រៀងតំបន់ទឹកប្រវត្តិសាស្ត្រឆ្នាំ១៩៨២ សន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋឆ្នាំ១៩៨៥ និង សន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០០៥ ទៅលើសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋឆ្នាំ១៩៨៥ ធ្វើជាមូលដ្ឋាន ក្នុងការកំណត់ព្រំដែន រវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម ។ រីឯ ការបោះបង្គោលព្រំដែនជាមួយវៀតណាមវិញ រដ្ឋាភិបាលនៃលោក **ហ៊ុន សែន** ធ្វើស្ងាត់ៗ ដោយពុំមានការចូលរួមពីចម្រុះភាគីជាតិ និងចម្រុះភាគីអន្តរជាតិ ដូចជាអ្នកជំនាញនៃប្រទេសបារាំង ដែលជាម្ចាស់ផែនទីដើមរបស់ប្រទេសកម្ពុជា ឬតំណាងសហប្រធាន នៃកិច្ចព្រមព្រៀងក្រុងប៉ារីស៍ ឬអ្នកបច្ចេកទេសអង្គការសហប្រជាជាតិ ។

### អំពីព្រំដែនគោក

ប្រទេសកម្ពុជា និងប្រទេសវៀតណាម មានបង្គោលព្រំដែនច្បាស់លាស់រួចហើយ ចំនួន ១២៤ បង្គោល តាមអនុសញ្ញាព្រំដែនកម្ពុជា-កូសាំងស៊ីនបារាំង ឆ្នាំ១៨៧៣ ជាមរតករបស់អាណានិគមបារាំង។ នៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៩៣ អតីតព្រះមហាក្សត្រ ព្រះបាទ **នរោត្តម សីហនុ** ក៏ធ្លាប់បានរំឭកឡើងវិញ នូវបង្គោលទាំង ១២៤ នេះ ទៅកាន់សហនាយករដ្ឋមន្ត្រីកម្ពុជា សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** និងលោក **ហ៊ុន សែន** ឲ្យប្រាប់មេដឹកនាំវៀតណាម **ត្រូវយកបង្គោលព្រំដែនសម័យអាណាព្យាបាលបារាំង ទាំង ១២៤ បង្គោល ទៅដាក់ត្រង់កន្លែងដើមវិញ ។**

ផ្ទុយទៅវិញ ពីឆ្នាំ១៩៨៦ ដល់ឆ្នាំ១៩៨៨ សាធារណរដ្ឋប្រជាមានិតកម្ពុជានៃលោក **ហ៊ុន សែន** ដែលលើកបន្តុបដោយកងទ័ពវៀតណាមឈ្លានពាន បានបោះបង្គោលជាមួយប្រទេសវៀតណាម ចំនួន ៧២បង្គោល ដោយប្រើសន្ធិសញ្ញាឆ្នាំ១៩៨៥។ រដ្ឋាភិបាលកម្ពុជានៃលោក **ហ៊ុន សែន** បានគប់គិតជាមួយវៀតណាម ប្រើសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០០៥ ដែលបំពេញទៅលើសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋឆ្នាំ១៩៨៥ បោះបានបង្គោលថ្មី ចំនួន ៣១៥បង្គោល (ឬ ៨៤%)។ ទាំងអស់នេះ គឺជាបង្គោលខុសច្បាប់ ដែលត្រូវបានបោះចូលជ្រៅក្នុងទឹកដីកម្ពុជា ព្រោះសន្ធិសញ្ញាឆ្នាំ១៩៨៥ និងសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០០៥ ដែលប្រើសម្រាប់បោះបង្គោល ក៏ខុសច្បាប់, បង្គោលទាំងនេះ ដែលត្រូវបានបោះខុសពីខ្សែព្រំដែន និងទីតាំងបង្គោលសម័យអាណានិគមបារាំង ក៏ខុសច្បាប់, បង្គោលទាំងនេះ ដែលត្រូវបានបោះ ដោយការបង្កើតខ្សែបន្ទាត់ព្រំដែនថ្មីសន្លាង ជាមួយវៀតណាម ហើយបំបាត់ចោលនូវខ្សែបន្ទាត់ព្រំដែនមិនកែប្រែ ក៏ខុសច្បាប់ គឺខុសពីអត្ថន័យនៃមាត្រា២ និងមាត្រា៥៥ នៃរដ្ឋធម្មនុញ្ញកម្ពុជា និងរំលោភកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ឆ្នាំ១៩៩១ ។

យើងខ្ញុំសូមរំឭកថា សន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋឆ្នាំ១៩៨៥ រវាងសាធារណរដ្ឋប្រជាមានិតកម្ពុជា ជាមួយប្រទេសវៀតណាម គឺជាសន្ធិសញ្ញាមិនស្មើភាពគ្នា និងធ្វើឡើងក្រោមការត្រួតត្រា ដោយកងទ័ពវៀតណាមឈ្លានពាន។ សន្ធិសញ្ញានេះ បានប្រើផែនទី ដែលភាគីទាំងពីរអះអាងថា ប្រភេទបោន (Bonne) ខ្នាត ១/១០០.០០០ ចំនួន ២៦ផ្ទាំង ប៉ុន្តែ បោះពុម្ពឡើងវិញនៅវៀតណាម ដែលចុះហត្ថលេខាដោយក្រុមប្រតិភូព្រំដែនឆ្នាំ១៩៨៥ និងផែនទីប្រភេទយូធីអឹម (UTM) ខ្នាត ១/៥០.០០០ ចំនួន ៤០ផ្ទាំង **ជាផែនទីមិនស្របច្បាប់** ដែលយោធាអាមេរិក ប្រើប្រាស់ក្នុងសម័យសង្គ្រាមវៀតណាម ។ រីឯផែនទីខ្នាត ១/២៥.០០០ ត្រូវបានរដ្ឋាភិបាល លោក **ហ៊ុន សែន** ធ្វើស្ងាត់ៗជាមួយវៀតណាម លាក់កំបាំងប្រជាពលរដ្ឋខ្មែរជាម្ចាស់ទឹកដី ដោយគ្រាន់តែប្រើពាក្យបន្លំថា *«ដូចមាននៅលើផែនទីបោន (Bonne) ខ្នាត ១/១០០.០០០»* ។

កំហុសដ៏ធ្ងន់ធ្ងរ នៃការប្រើប្រាស់ផែនទី និងសន្ធិសញ្ញាខុសច្បាប់ទាំងអស់នេះ ធ្វើឲ្យពលរដ្ឋខ្មែរនៅតាមព្រំដែន **«ស្រែកយំ ព្រោះបាត់បង់ដីស្រែចម្ការ»** រហូតដល់បាត់ទាំងភូមិកំណើតរបស់លោក **ហេង សំរិន** ប្រធានរដ្ឋសភា និងជាប្រធានកិត្តិយសគណបក្សប្រជាជនកម្ពុជា ដែលកំពុងកាន់អំណាចផង។ នេះគឺផ្ទុយទាំងស្រុង ពីការអះអាងរបស់លោក **ហ៊ុន សែន** ដែលថា «ចំណេញដីជាង ២០០០ហិកតា ពីការដោះដូរព្រំដែនជាមួយវៀតណាម» ពីព្រោះមិនដែលបានឃើញជនជាតិខ្មែររូបណា ទោះពលរដ្ឋសាមញ្ញ កសិករ មន្ត្រីរាជការ ឬកងកម្លាំងប្រដាប់អាវុធ ទទួលបានដីពីការផ្តល់ឲ្យដោយវៀតណាមទេ គឺមានតែពលរដ្ឋខ្មែរគ្រប់តំបន់ជាប់ព្រំដែន នាំគ្នាយំបាត់ដី ហើយក៏មិនដែលជួបប្រជាជនវៀតណាមម្នាក់ណា ត្អូញត្អែររឿងបាត់ដីរបស់ខ្លួន មកខាងកម្ពុជាឡើយ ។

## អំពី ដែនសមុទ្រ កោះត្រល់ និងចង្កោមកោះក្រចកសេះ

លោក **ហ៊ុន សែន** ទើបតែទទួលស្គាល់ថា **កោះត្រល់ (ភូកុក)** និង**ចង្កោមកោះក្រចកចេះ (ថូជូ)** ជាកម្មសិទ្ធិរបស់វៀតណាម ដោយរំលោភលើប្រវត្តិសាស្ត្រ ភូមិសាស្ត្រ និង គោលការណ៍ច្បាប់ជាតិ-អន្តរជាតិនានាជាធរមាន ក្រោយពីមានកិច្ចព្រមព្រៀងតំបន់ទឹកប្រវត្តិសាស្ត្រឆ្នាំ១៩៨២ប៉ុណ្ណោះ ។ ឯកសារព្រំដែនរបស់លោក **ស៊ាន ម៉េងសែ** បញ្ជាក់ថា *«ដោយសំអាងលើកិច្ចព្រមព្រៀងតំបន់ទឹកប្រវត្តិសាស្ត្រឆ្នាំ១៩៨២នេះ ដែនសមុទ្រកម្ពុជា ដែលមានទំហំសរុប ៩៥.០០០ (កៅសិបប្រាំពាន់)គ.ម.ក្រឡា ត្រូវបានប្រទេសវៀតណាម នៅថ្ងៃទី៧ ខែសីហា ឆ្នាំ១៩៩៧ ធ្វើកិច្ចព្រមព្រៀងថ្មីមួយ ជាមួយប្រទេសថៃ ស្តីពីការកំណត់ដែនសមុទ្រ ដោយរំលងលើក្បាលខ្មែរ (លោក **ហ៊ុន សែន**) និងយកដែនសមុទ្រខ្មែរ ចែកជាមួយប្រទេសថៃឡង់ដ៍ ទំហំប្រមាណ ៣០.០០០(សាមសិបពាន់)គ.ម.ក្រឡា រៀងៗខ្លួន»* ។

កិច្ចព្រមព្រៀងតំបន់ទឹកប្រវត្តិសាស្ត្រនេះ ត្រូវបានប្រទេសសិង្ហបុរី រាយការណ៍ទៅកាន់មហាសន្និបាតអង្គការសហប្រជាជាតិ នៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ១៩៨៦ បញ្ជាក់ថា កម្ពុជាត្រូវវៀតណាមបង្ខំឲ្យចុះហត្ថលេខា នៅពេលវៀតណាមចូលឈ្លានពានត្រួតត្រាប្រទេសកម្ពុជា ចាប់តាំងពីចុងឆ្នាំ១៩៧៨មក ហើយរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា នាពេលនោះ មិនមែនជាតំណាងស្របច្បាប់របស់ប្រទេស ឬតំណាងផលប្រយោជន៍ នៃពលរដ្ឋខ្មែរទេ គឺមានតែរដ្ឋាភិបាលចម្រុះត្រីភាគី នៃសម្តេចព្រះ **នរោត្តម សីហនុ** តែមួយគត់ ដែលត្រូវបានទទួលស្គាល់ ដោយអង្គការសហប្រជាជាតិ ។

បន្ថែមលើសេចក្តីរាយការណ៍របស់ប្រទេសសិង្ហបុរី ទៅកាន់អង្គការសហប្រជាជាតិឆ្នាំ១៩៨៦ សហរដ្ឋអាមេរិកក៏បានតវ៉ាជំទាស់នឹងកិច្ចព្រមព្រៀងតំបន់ទឹកប្រវត្តិសាស្ត្រឆ្នាំ១៩៨២នេះដែរ នៅក្នុងសេចក្តីថ្លែងការណ៍ ទៅកាន់អង្គការសហប្រជាជាតិ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៨៧ ។ ប្រទេសថៃ សិង្ហបូរី និង ប្រទេសអាល្លឺម៉ង់ ក៏បានចូលរួមជាមួយសហរដ្ឋអាមេរិក ក្នុងការប្រឆាំងចំពោះការកាត់ឆ្វៀលយកកោះត្រល់ និងចង្កោមកោះក្រចកសេះរបស់កម្ពុជា ទៅក្រោមការគ្រប់គ្រងរបស់វៀតណាម ដោយរំលោភបំពានលើអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីច្បាប់សមុទ្រ ឆ្នាំ១៩៨២ ។

លើសពីនេះ កិច្ចព្រមព្រៀងតំបន់ទឹកប្រវត្តិសាស្ត្រឆ្នាំ១៩៨២ ត្រូវបានដាក់ជាមោឃភាពរួចហើយ ដោយកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសឆ្នាំ១៩៩១ និងមាត្រា៥៥ នៃរដ្ឋធម្មនុញ្ញកម្ពុជា ។

ប៉ុន្តែ លោក **ហ៊ុន សែន** បែរជានៅតែមានះ បន្តអះអាងទាំងបំពាន រហូតដល់ពេលនេះថា **កោះត្រល់ និងចង្កោមកោះក្រចកសេះ** បានបាត់បង់ទៅវៀតណាម តាំងពីឆ្នាំ១៩៣៩ តាមលិខិតរបស់លោក **ប្រេវីយេ** (Jules Brévie) អគ្គទេសាភិបាលបារាំងនៅឥណ្ឌូចិនទៅវិញ ។

តាមពិត ខ្លឹមសារលិខិតរបស់លោក **ប្រេវីយេ** (Jules Brévié) នៅថ្ងៃទី ៣១ ខែមករា ឆ្នាំ១៩៣៩ បង្ហាញថា *«កោះត្រល់ ត្រូវដាក់ឲ្យខាងកូសាំងស៊ីន គ្រប់គ្រងខាងផ្នែករដ្ឋបាល និងប៉ូលីសប៉ុណ្ណោះ»* ។ **លិខិតនេះ បញ្ជាក់ថា កោះនេះនៅតែជាកម្មសិទ្ធិរបស់ប្រទេសកម្ពុជា ដោយផ្អែកតាមភូមិសាស្ត្រជាក់ស្តែង និងសណ្ឋានដីបាតសមុទ្រ ជុះភ្ជាប់ឆ្នេរខេត្តកំពត នៃប្រទេសកម្ពុជា។** លោក **ប្រេវីយេ** មិនបានភ្ជាប់ករណីកោះត្រល់ និងចង្កោមកោះក្រចកសេះ ទាក់ទងនឹងការផ្ទេរដែនដីកូសាំងស៊ីន (កម្ពុជាក្រោមសព្វថ្ងៃ) ទៅឲ្យវៀតណាមនៅឆ្នាំ១៩៤៩ ទេ ។

អនុសញ្ញាស្តីអំពីច្បាប់សមុទ្រឆ្នាំ១៩៨២ ផ្នែក២ ជំពូក២ មាត្រា៣ ចែងថា *«រដ្ឋទាំងអស់មានសិទ្ធិ បង្កើតប្រវែងនៃដែនសមុទ្ររបស់ខ្លួន រហូតដល់ដែនកំណត់ មិនលើសពីចម្ងាយ* ***១២ ម៉ាយល៍ ឬស្មើ ២២,២២៤ គីឡូម៉ែត្រ (1 nautical miles=1,852 meters)*** *ដែលវាស់ពីខ្សែបន្ទាត់មូលដ្ឋានដែនកំណត់ អនុលោមតាមអនុសញ្ញានេះ»* ។ អនុសញ្ញាឆ្នាំ១៩៨២នេះ និងតាមលក្ខខណ្ឌភូមិសាស្ត្រ កោះត្រល់ គឺជាកម្មសិទ្ធិរបស់ប្រទេសកម្ពុជា ពីព្រោះកោះត្រល់ មានរយៈចម្ងាយត្រឹមតែ ១៥ គីឡូម៉ែត្រ ពីឆ្នេរសមុទ្រខេត្តកំពត ប្រទេសកម្ពុជា ក្នុងរង្វង់ដែន ២២,២២៤ គីឡូម៉ែត្រ ដែលកំណត់ដោយច្បាប់សមុទ្រ ប៉ុន្តែកោះត្រល់ មានរយៈចម្ងាយរហូតដល់ ៤៥ គីឡូម៉ែត្រ ពីតំបន់ហាទៀង ខេត្តកៀនយ៉ាង វៀតណាម ដែលស្ថិតនៅផ្នែខាងក្រៅរង្វង់ដែន ២២,២២៤ គីឡូម៉ែត្រ កំណត់ដោយច្បាប់សមុទ្រនេះ ។

**ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ** ចាត់ទុកថា សុន្ទរកថារយៈពេលជាង៥ម៉ោងរបស់លោក **ហ៊ុន សែន** នៅរដ្ឋសភាជាតិ កាលពីថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១២ គឺជាវិធីបន្លំដានប្រវត្តិសាស្ត្រ ដែលយើងខ្ញុំមិនអាចទទួលយកបានឡើយ ពីព្រោះកម្ពុជាមានបង្គោល និងខ្សែព្រំដែនជាក់លាក់ តាំងពីសម័យអាណានិគមនិយមបារាំងម្ល៉េះ ដែលទទួលស្គាល់ជាអន្តរជាតិ ។

សន្ទរកថានេះ ក៏គឺជាបណ្តាសា ចំពោះប្រជាជាតិខ្មែរទាំងមូល ព្រោះការបោះបង្គោលព្រំដែនរវាងរដ្ឋាភិបាលលោក **ហ៊ុន សែន** និងវៀតណាម ធ្វើឲ្យពលរដ្ឋខ្មែរនៅតាមព្រំដែនស្រែកយំបាត់ដីស្រែចម្ការផង ហើយបំបាក់ស្មារតីសកម្មជនខ្មែរ ដែលតវ៉ារឿងបាត់បង់ទឹកដីព្រំដែន ដោយចាប់ដាក់គុក និងគំរាមកំហែងអាយុជីវិតផង។ ដើម្បីបញ្ចៀសនូវបណ្តាសាកាន់តែខ្មៅងងឹតសង្កត់ប្រជាជាតិខ្មែរ រដ្ឋាភិបាលត្រូវតែដោះលែងអ្នកទោសមនសិការទឹកដីជាតិ ពីពន្ធនាគារ ដូចជាលោក **រ៉ុង ឈុន**, យុវជន **ហ៊ុន វណ្ណៈ**, យុវតី **ឈឿន ដារ៉ាវី**, កញ្ញា **ស កន្និកា**, លោក **សួង សុភ័ណ្ឌ** និងអ្នកផ្សេងទៀត ។

**ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ** សូមរំឭកលោកនាយករដ្ឋមន្ត្រីថា ការឈឺឆ្អាលអំពីបញ្ហាព្រំដែនរបស់យើងខ្ញុំជាបញ្ញវន្ត ក៏ដូចបងប្អូនប្រជាពលរដ្ឋខ្មែរ គឺជាសម្រែកឈឺចាប់នៃជនរងគ្រោះ និងមិនមែនជាការបង្កសង្គ្រាមជាមួយប្រទេសណាមួយនោះទេ ទោះជាវៀតណាម ដែលមានប្រវត្តិជាប់មិនដាច់ក្នុងការឈ្លានពានកម្ពុជា ជាក់ស្តែង ការបោះតង់យ៉ាងតិច ២៨៣កន្លែង នៅតាមបណ្តោយព្រំដែនខ្មែរ ។ តើលោកនាយករដ្ឋមន្ត្រី **ហ៊ុន សែន** នៅខាងប្រជាពលរដ្ឋខ្មែរ ឬការពារផលប្រយោជន៍របស់វៀតណាម ?

**ជ.គណៈកម្មាធិការប្រតិបត្តិ**

**អនុប្រធាន**

**អ៊ិប សេង**

2402 24TH ST SE, WASHINGTON, DC 20020 | TEL: (202) 430-5503 | EMAIL: INFO@SMD2.NET | WWW.SMD2.NET